**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៧៧........[illegible]

# សេចក្តីថ្លែងហេតុ
# នៃសេចក្តីព្រាងច្បាប់
# ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤

## I- សេចក្តីផ្តើម

១-សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ត្រូវបានរៀបចំក្នុងបរិការណ៍ដែលសេដ្ឋកិច្ចកម្ពុជា បាននិងកំពុងបង្ហាញនូវភាពមាំមួនឆ្ពោះទៅរកគោលដៅគោល-នយោបាយកំណើនប្រចាំឆ្នាំ៧% របស់រាជរដ្ឋាភិបាល ព្រមទាំងឆ្ពោះទៅសម្រេចបានតាមគោលដៅសំខាន់ៗនៃការអភិវឌ្ឍ ទោះបីជាកំណើននេះនៅមានលក្ខណៈផុយស្រួយនិងហានិភ័យខ្ពស់នៅឡើយ ដោយសារភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចពិភពលោកនិងគ្រោះធម្មជាតិជាបន្តបន្ទាប់។ ចលនការសេដ្ឋកិច្ចនេះ កំពុងស្ថិតក្នុងក្របខ័ណ្ឌនៃដំណើរផ្លាស់ប្តូរ ទាំងបរិមាណនិងគុណភាពនៅក្នុងគ្រប់ទិដ្ឋភាពនៃសង្គមកម្ពុជា ទាំងក្នុងទិដ្ឋភាពសង្គម សេដ្ឋកិច្ច និងស្ថានភាពប្រជាសាស្ត្រ។ ទន្ទឹមនឹងនេះ សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ក៏ត្រូវបានរៀបចំដើម្បីឆ្លើយតបទៅនឹងឆន្ទៈរបស់ប្រជាជនដែលបានសម្តែងឡើង តាមរយៈលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ដែលបានប្រព្រឹត្តទៅស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងនីតិរដ្ឋ ដែលត្រូវបានសាធារណៈមតិជាតិនិងអន្តរជាតិវាយតម្លៃថា ជាការបោះឆ្នោតដោយសេរី យុត្តិធម៌ និងមានសន្តិសុខល្អ គ្មានការគម្រាមកំហែង គ្មានអំពើហិង្សា។

២- ជាក់ស្តែង រាជរដ្ឋាភិបាលនីតិកាលទី៣និងទី៤នៃរដ្ឋសភា បានអនុវត្តប្រកបដោយជោគជ័យនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១និងទី២ ដោយមិនត្រឹមតែរក្សាបាននូវស្ថិរភាពនយោបាយ សន្តិសុខ សុវត្ថិភាពសង្គម និងរក្សាបាននូវអធិបតេយ្យ បូរណភាពទឹកដី ព្រមទាំងរក្សាបានស្ថិរភាពហិរញ្ញវត្ថុនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដោយជម្នះបាននូវផលប៉ះពាល់នៃវិបត្តិកលិយុគសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកលលោក ព្រមទាំងវិបត្តិគ្រោះទឹកជំនន់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនាំមកនូវកេរ្តិ៍ឈ្មោះ ដែលកម្ពុជាត្រូវបានវាយតម្លៃថាជាប្រទេសទី១១ លើពិភពលោកដែលសម្រេចបានកំណើន

សេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេល១០ឆ្នាំចុងក្រោយ និងជាប្រទេសទី៥ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ ដែលអាចនឹងសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ព្រមទាំងស្ថិតក្នុងចំណាត់ថ្នាក់ទី១នៅអាស៊ី-ប៉ាស៊ីហ្វិក ដែលសម្រេចបាននូវវឌ្ឍនភាពល្អប្រសើរក្នុងការកែលម្អសូចនាករផ្នែកសង្គមកិច្ច ជាពិសេស កាត់បន្ថយភាពក្រីក្រក្នុងអត្រាជាង១% ក្នុងមួយឆ្នាំ។

៣- ជាមួយនឹងសមិទ្ធផលដែលទទួលបានធំៗខាងលើ កម្ពុជានៅបន្តជួបនឹងបញ្ហាប្រឈមមួយចំនួន ដូចជា ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិភពលោក ដុល្លារូបនីយកម្មនៃសេដ្ឋកិច្ចកម្ពុជា ភាពចាំបាច់ក្នុងការកែលម្អថែមទៀតនូវគុណភាពសេវាសាធារណៈនិងសេវាយុត្តិធម៌ ថ្លៃដឹកជញ្ជូននិងថ្លៃអគ្គិសនីខ្ពស់ធៀបនឹងប្រទេសជិតខាង និងជាពិសេស សេចក្តីត្រូវការក្នុងការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពនិងសមត្ថភាព ដែលជាកត្តាគន្លឹះសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងភាពប្រកួតប្រជែងរបស់ប្រទេស ទាំងក្នុងពេលចំពោះមុខនិងទាំងសម្រាប់អនាគតរយៈពេលវែង។ ទន្ទឹមនឹងនេះ លទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ក៏បានឆ្លុះបញ្ចាំងនូវឆន្ទៈរបស់ប្រជាជន ដែលចង់ឲ្យរាជរដ្ឋាភិបាលដោះស្រាយបញ្ហាសេដ្ឋកិច្ចនិងសង្គមជាមូលដ្ឋាន ដែលពាក់ព័ន្ធដល់ជីវភាពប្រចាំថ្ងៃរបស់ប្រជាជន ឲ្យកាន់តែមានប្រសិទ្ធភាពជាងមុន។

ឈរលើមូលដ្ឋានខាងលើនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវ **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ ដើម្បី កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព** ដែលជា "**របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច**" នៃ "**កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា**" ដែលមាន "**គោលដៅជាយុទ្ធសាស្ត្រ ៤**" គឺៈ

ទី១- ធានាឲ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាមធ្យមប្រចាំឆ្នាំប្រមាណ ៧% ប្រកបដោយចីរភាព បរិយាប័ន្ន សមធម៌ និងធន់នឹងវិបត្តិ តាមរយៈការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចឱ្យបានទូលាយនិងមានសមត្ថភាពប្រកួតប្រជែងជាងមុន ក្នុងបរិការណ៍អតិផរណាមានកម្រិតទាបអាចគ្រប់-គ្រងបាន អត្រាប្តូរប្រាក់មានស្ថិរភាព និងទុនបម្រុងមានកំណើនជាប្រចាំ។

ទី២- បង្កើតការងារឱ្យបានកាន់តែច្រើនឡើងជូនដល់ប្រជាជន ពិសេសសម្រាប់ស្រទាប់យុវជន តាមរយៈការបន្តខិតខំកែលម្អនិងបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងការទាក់ទាញនិងការជំរុញលើកទឹកចិត្តដល់សកម្មភាពវិនិយោគ ទាំងវិនិយោគក្នុងប្រទេស ទាំងវិនិយោគមកពីក្រៅប្រទេស។

ទី៣- សម្រេចឲ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រក្នុងអត្រាជាង ១% ក្នុងមួយឆ្នាំ ក៏ដូចជាគោលដៅផ្សេងទៀតដែលត្រូវបានកំណត់ក្នុង **"គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា"** ទន្ទឹមនឹងការផ្តោតអាទិភាពកាន់តែខ្លាំងឡើងលើការអភិវឌ្ឍធនធានមនុស្ស ការគ្រប់គ្រងបរិស្ថាន និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព។

ទី៤- បន្តពង្រឹងសមត្ថភាពនិងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ដើម្បីធានាឲ្យបាននូវប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិនៃសេវាសាធារណៈ សំដៅបម្រើប្រជាជនឲ្យកាន់តែប្រសើរឡើង។

៤- លើសពីនេះ ថវិកាឆ្នាំ២០១៤ ក៏ត្រូវបានរៀបចំឡើងក្នុងគោលដៅផ្តល់ការយកចិត្តទុកដាក់លើ "**វិស័យអាទិភាព ៤**" នៃយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ គឺ ៖

ទី១- ការអភិវឌ្ឍធនធានមនុស្សនិងការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ដោយផ្តោតជាពិសេសលើយុវជន។

ទី២- ការបន្តវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងការកែលម្អថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្ម ដើម្បីបង្កើនភាពទាក់ទាញនិងភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា។

ទី៣- ការបន្តអភិវឌ្ឍវិស័យកសិកម្ម ក្នុងគោលដៅជំរុញកំណើនសេដ្ឋកិច្ចនិងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ព្រមទាំងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ តាមរយៈការបង្កើនផលិតភាព ទំនើបកម្មកសិកម្ម ឧស្សាហូបនីយកម្ម និងការលើកកម្ពស់ពាណិជ្ជូបនីយកម្ម។

ទី៤- ការពង្រឹងអភិបាលកិច្ចនិងសមត្ថភាពនៃស្ថាប័នរដ្ឋ សំដៅបង្កើនប្រសិទ្ធភាពនិងគុណភាពសេវាសាធារណៈ និងបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងការវិនិយោគនិងធុរកិច្ច ពិសេសការកែលម្អបរិស្ថានវិនិយោគ តាមរយៈការកាត់បន្ថយថ្លៃដើមនិងរបាំងធុរកិច្ច។

៥- ដើម្បីធានាឲ្យបានតាមគោលដៅយុទ្ធសាស្ត្រខាងលើ ជាពិសេស ដើម្បីបន្តធានានិងជំរុញឲ្យកាន់តែមានប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិ នូវការបន្តអនុវត្តកម្មវិធីគោលនយោបាយវិស័យអាទិភាពដែលបានគូសបញ្ជាក់ខាងលើ គោលនយោបាយថវិកាឆ្នាំ២០១៤ បានបង្កើនចំណាយបន្ទុកបុគ្គលិកពីកម្រិតគោល ៤០%នៃចំណាយចរន្ត ឲ្យឡើងរហូតដល់ជាង ៤៥%នៃចំណាយចរន្តសរុប ដែលស្មើប្រមាណជាង ៥%នៃផ.ស.ស ក្នុងគោលដៅបង្កើនភាពស័ក្តិសិទ្ធិនិងផលិតភាពការងារ ទន្ទឹមនឹងការបន្តសន្សំសំចៃចំណាយក្រៅបន្ទុកបុគ្គលិក និងការជំរុញការបង្កើនប្រសិទ្ធភាពចំណាយសាធារណៈ។ លើសពីនេះ រាជរដ្ឋាភិបាលនឹងបន្តជំរុញអនុវត្តឲ្យកាន់តែស៊ីជម្រៅថែមទៀតនូវកំណែទម្រង់សំខាន់ ៣ ប្រទាក់ក្រឡាគ្នា គឺកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់វិសហមជ្ឈការនិងវិមជ្ឈការ និងកំណែទម្រង់រដ្ឋបាលសាធារណៈរួមទាំងកំណែទម្រង់បៀវត្សផង ព្រមទាំងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដែលជាស្នូលនៃអភិបាលកិច្ចល្អនិងជាគន្លឹះក្នុងការបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃសេវាសាធារណៈជូនប្រជាពលរដ្ឋ។

## II- គោលនយោបាយនិងក្របខ័ណ្ឌថវិកាឆ្នាំ២០១៤

### ២-១. ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១៤

៦- ការប្រកាន់ខ្ជាប់ខ្ជួននូវការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសមស្រប គួបផ្សំនឹងការអនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយភាពប្រុងប្រយ័ត្ន បានធ្វើឲ្យកម្ពុជាសម្រេចបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងកំណើនសេដ្ឋកិច្ចខ្ពស់រយៈពេលវែង ទោះបីជាមានផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ចពិភពលោក ក៏ដូចជាគ្រោះធម្មជាតិជាបន្តបន្ទាប់ក៏ដោយ។ ជាក់ស្តែងក្នុងឆ្នាំ២០០៩ ជាឆ្នាំដែលកម្ពុជាបានទទួលផលប៉ះពាល់ពីវិបត្តិនេះក៏ដោយ ក៏

សេដ្ឋកិច្ចកម្ពុជាសម្រេចបាននូវកំណើនវិជ្ជមានគឺ ០,១%, ក្នុងឆ្នាំ២០១០ មានកំណើន ៦%, ក្នុងឆ្នាំ ២០១១ មានកំណើន ៧,១%។

តាមការគណនារបស់វិទ្យាស្ថានជាតិស្ថិតិបង្ហាញថា កំណើនសេដ្ឋកិច្ចនៅឆ្នាំ២០១២ សម្រេចបាន ៧,៣% ក្នុងនោះវិស័យកសិកម្មសម្រេចបានកំណើន ៤,៣% វិស័យឧស្សាហកម្មសម្រេចបានកំណើន៩,៣% និងវិស័យសេវា សម្រេចបានកំណើន ៨,១%។ តាមការប៉ាន់ស្មានដោយប្រុងប្រយ័ត្នប្រយែងនិងដោយផ្អែកលើនិន្នាការសេដ្ឋកិច្ចដើមឆ្នាំនេះ កំណើនសេដ្ឋកិច្ចឆ្នាំ២០១៣នេះអាចនឹងសម្រេចបាន ៧,៦% ខ្ពស់ជាងការគ្រោងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។ កំណើននេះនឹងបានមកពីកំណើនវិស័យកសិកម្មប្រមាណ ៤,២% ដោយសារការបន្តកើនឡើងនៃដំណាំស្រូវ ដំឡូងមី កៅស៊ូ និងអំពៅ។ វិស័យឧស្សាហកម្មនឹងមានកំណើន ៩,៣% ដោយសារការបន្តកើនឡើងនៃផ្នែកវាយនភណ្ឌ ការរីកចម្រើនវិស័យឧស្សាហកម្មធុនស្រាល និងផលិតផលនៃខ្សែចង្វាក់ផ្គត់ផ្គង់សកល។ វិស័យសេវានឹងមានកំណើន ៨,៨% ដែលបានមកពីកំណើនវិស័យដឹកជញ្ជូននិងទូរគមនាគមន៍ វិស័យទេសចរណ៍ វិស័យហិរញ្ញវត្ថុ និងវិស័យអចលនទ្រព្យ។ អតិផរណានឹងស្ថិតក្នុងរង្វង់ ៣% ជាមួយនឹងអត្រាប្តូរប្រាក់ក្នុងរង្វង់ ៤ ០៥០រៀលក្នុងមួយដុល្លារអាមេរិក។ ឱនភាពគណនីចរន្តជញ្ជីងទូទាត់ក្រៅប្រទេស នឹងត្រូវបានកាត់បន្ថយពី-១០,២% នៃផ.ស.ស. ក្នុងឆ្នាំ២០១២ មក -៩,៥% នៃផ.ស.ស. ក្នុងឆ្នាំ២០១៣។

ជារួមក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ សេដ្ឋកិច្ចកម្ពុជាបាននិងកំពុងបង្ហាញនូវភាពមាំមួនជាមួយនឹងការសម្រេចបានគោលដៅកំណើនប្រចាំឆ្នាំ៧% នៅក្នុងក្របខ័ណ្ឌអតិផរណាទាបក្នុងរង្វង់ ៣%។ ប្រការនេះបានរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ការទាក់ទាញវិនិយោគ និងបង្កើតការងារបានច្រើន។

**៧-** កំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៤ តាមការព្យាករ អាចនឹងបន្តសម្រេចបានក្នុងរង្វង់ ៧%។ កំណើននេះនឹងបានមកពីកំណើនវិស័យកសិកម្មប្រមាណ ៤,២% ដោយសារការកើនឡើងនៃកសិផលសម្រាប់ប្រើប្រាស់ក្នុងស្រុកនិងតម្រូវការទីផ្សារអន្តរជាតិមានដូចជា ស្រូវ ពោត ដំឡូងមី កៅស៊ូ និងអំពៅជាដើម។ វិស័យឧស្សាហកម្មអាចនឹងមានកំណើនប្រមាណ ៩,៩% ដោយរំពឹងថាវិស័យវាយនភណ្ឌនឹងអាចកើនឡើងប្រមាណ ៨,៧% ដោយសារការនាំចេញទៅសហគមន៍អឺរ៉ុបនៅបន្តរួចពន្ធក្រោមកម្មវិធី "ទំនិញគ្រប់មុខ លើកលែងតែសព្វាវុធ" និងសក្តានុពលដែលអាចពង្រីកផលិតកម្មនិងទីផ្សារនៃវិស័យនេះ គួបផ្សំនឹងការងើបឡើងវិញនៃសេដ្ឋកិច្ចអឺរ៉ុបនិងអាមេរិក។ លើសពីនេះ គម្រោងវិនិយោគមួយចំនួនក្នុងវិស័យអគ្គិសនី ទាំងវារីអគ្គិសនី ទាំងអគ្គិសនីប្រើប្រាស់ធ្យូងថ្ម នឹងត្រូវបានដាក់ឲ្យដំណើរការជាបន្តបន្ទាប់និងឧស្សាហកម្មធុនស្រាលដទៃទៀត ក៏បង្កើនសកម្មភាពកាន់តែខ្លាំងក្លាដែរ។ ម្យ៉ាងទៀត គោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករក៏បានជំរុញឲ្យមានការកើនឡើងនូវការនាំចេញអង្ករ និងអភិវឌ្ឍវិស័យកែច្នៃកសិផលនិងវិស័យដែលទាក់ទងមួយចំនួនទៀត ដែលបានបង្កើនតម្លៃបន្ថែមលើផលិតផលដែលមានស្រាប់។ វិស័យសេវាអាចនឹងសម្រេចបានកំណើនប្រមាណ ៦,៨% ដោយសារការកើនឡើងនៃវិស័យទេសចរណ៍ វិស័យដឹកជញ្ជូន វិស័យហិរញ្ញវត្ថុ

វិស័យអចលនទ្រព្យ និងវិស័យសេវាផ្សេងៗទៀត។ សកម្មភាពសេដ្ឋកិច្ចទូទៅដែលជួយជំរុញកំណើនសេដ្ឋកិច្ចនឹងបន្តកើនឡើងក្នុងល្បឿនលឿន ដោយសារការអនុវត្តគោលនយោបាយហិរញ្ញវត្ថុនិងគោលនយោបាយរូបិយវត្ថុប្រុងប្រយ័ត្ន ក៏ដូចជាគោលនយោបាយជំរុញហិរញ្ញប្បទានក្នុងក្របខ័ណ្ឌគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ និងគោលនយោបាយលើកស្ទួយសហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យឧស្សាហកម្ម។

៨- ផ្អែកលើលទ្ធផលនៃការអនុវត្តឆ្នាំ២០១២និងការគណនាសម្រាប់ឆ្នាំ២០១៣ ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៤ ត្រូវបានកំណត់ជាសូចនាករសំខាន់ៗដូចខាងក្រោម:

- កំណើនសេដ្ឋកិច្ចតាមថ្លៃថេរនឹងសម្រេចបានក្នុងរង្វង់៧% ដែលធ្វើឲ្យផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) គិតជាទឹកប្រាក់តាមថ្លៃបច្ចុប្បន្នមានចំនួន៦៨ ៦១៩ ០០០លានរៀល ដែលត្រូវជាប្រមាណ១៦ ៩៤៣លានដុល្លារអាមេរិក។ ដូច្នេះ នៅឆ្នាំ២០១៤ ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់អាចនឹងឡើងដល់ ១ ១៣៩ដុល្លារអាមេរិក ហើយធ្វើឲ្យកម្ពុជាអាចនឹងចេញផុតពីចំណាត់ថ្នាក់ជាប្រទេសមានចំណូលទាប (Low Income Status-LIS) ក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប (Lower Middle-Income Status-LMIS) ក្នុងពេលឆាប់ៗខាងមុខ។
- អតិផរណានឹងត្រូវបានរក្សាឲ្យស្ថិតក្នុងរង្វង់៣,៥% ដោយរាជរដ្ឋាភិបាលនឹងបន្តអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈនិងគោលនយោបាយរូបិយវត្ថុសមស្របនិងប្រុងប្រយ័ត្ន។
- អត្រាប្តូរប្រាក់រៀល-ដុល្លារអាមេរិកនឹងត្រូវបានរក្សាឲ្យស្ថិតក្នុងរង្វង់ ៤ ០៥០រៀល ក្នុង ១ដុល្លារអាមេរិក។
- ឱនភាពគណនីចរន្តនៃជញ្ជីងទូទាត់ក្រៅប្រទេស នឹងត្រូវបានកាត់បន្ថយពី -៩,៥%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៣ មកត្រឹម-៩,៣%នៃផ.ស.ស. ក្នុងឆ្នាំ២០១៤ ដោយសារការកើនឡើងនៃការនាំចេញ ជាពិសេស កំណើននៃការនាំចេញទំនិញពីវិស័យកសិកម្មនិងវិស័យអេឡិត្រូនិច។ ឱនភាពគណនីចរន្តនៃជញ្ជីងទូទាត់នៅមានកម្រិតខ្ពស់ ហើយកម្ពុជាត្រូវបន្តខិតខំកាត់បន្ថយឲ្យនៅកម្រិតសមស្របក្នុងរយៈពេលមធ្យមខាងមុខ។

## ២-២. ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៤

**៩- ផ្អែកលើគោលនយោបាយដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣និងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចខាងលើ ថវិកាឆ្នាំ២០១៤ បានដាក់ចេញគោលដៅសំខាន់ៗដូចតទៅ៖**

- ធានាបន្តអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាល *ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព សំដៅសម្រេចគោលដៅនៃការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន* ដោយធានាបានទាំងស្រុងនូវការអនុវត្ត *គោលនយោបាយអាទិភាពនិងផែនការតាមវិស័យទាំងឡាយរបស់រាជរដ្ឋាភិបាល* ដែលត្រូវបានដាក់ចេញនៅក្នុង "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣**"។
- ធានាបន្តរក្សាសន្តិភាព សន្តិសុខ សុវត្ថិភាព សេរីភាព ប្រជាធិបតេយ្យ និងសុភមង្គលជូនប្រជាពលរដ្ឋ ព្រមទាំងធានាការពារឲ្យបានទាំងស្រុងនូវអធិបតេយ្យជាតិនិងបូរណភាពទឹកដី។

• ធានាបន្តសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព ស្ថិរភាពម៉ាក្រូ-សេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ ក្នុងបរិការណ៍នៃអត្រាអតិផរណាទាបនិងអត្រាប្តូរប្រាក់មានស្ថិរភាព។

• ពង្រឹងភាពធន់ទល់នឹងវិបត្តិនិងបរិយាប័ន្នភាពនៃសេដ្ឋកិច្ច ព្រមទាំងចីរភាពនៃថវិកា។

• ធានាបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈរំកិល៣ឆ្នាំ២០១៤-២០១៦ ជាពិសេសបង្កើនការវិនិយោគលើវិស័យអប់រំ សុខាភិបាល កសិកម្ម អភិវឌ្ឍជនបទ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធទាំងឡាយ ដែលទទួលរងនូវការខូចខាតដោយទឹកជំនន់ឆ្នាំ២០១៣។

• អនុវត្តដំណាក់កាលទី១ នៃកម្មវិធីកំណែទម្រង់ប្រព័ន្ធបៀវត្សដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ តាមគោលការណ៍ដែលធានាបាននូវសង្គតិភាព សមធម៌ ផលិតភាពការងារ និងត្រូវផ្អែកលើភាពទ្រទ្រង់បាននៃថវិកាជាតិ។

• បន្តអនុវត្តកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ដើម្បីធានាយុត្តិធម៌សង្គម ព្រមទាំងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ សុចរិតភាព តម្លាភាព និង គណនេយ្យភាព។

• បន្តអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការព្រមទាំងពង្រឹងស្ថាប័នត្រួតពិនិត្យ ដើម្បីបង្កើនប្រសិទ្ធភាពនិងគុណភាពសេវាសាធារណៈជូនប្រជាជន។

• បន្តជំរុញអនុវត្តគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ និងការអភិវឌ្ឍជនបទ។

## ២-៣. គម្រោងចំណូល-ចំណាយថវិការដ្ឋឆ្នាំ២០១៤

១០- *ក្នុងក្របខ័ណ្ឌនៃគោលដៅខាងលើ រាជរដ្ឋាភិបាលនឹងត្រូវការថវិកាចំណាយសរុបចំនួន ១៤ ១៦៧ ៤៤៩,៣លានរៀល ស្មើនឹង២០,៦៥%នៃផ.ស.ស. គឺកើនឡើង១៣,១% ត្រូវជា ០,២៨% នៃផ.ស.ស. ធៀបនឹងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។* **ចំណាយថវិការដ្ឋឆ្លងរតនាគារជាតិ** មានចំនួន១០ ៧០៧ ៤៤៩,៣លានរៀល កើនឡើង១៤,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៣ ស្មើនឹង១៥,60% នៃផ.ស.ស. ក្នុងនោះចំណាយថវិកាថ្នាក់ជាតិសរុបមានចំនួន ១០ ១៣៥ ៦២៧លានរៀល កើនឡើង១៣,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៣ គឺស្មើនឹង ១៤,៧៧%នៃផ.ស.ស. និងចំណាយថវិកាថ្នាក់ក្រោមជាតិសរុបមានចំនួន៧៤៤ ២៩៣,៥លានរៀល កើនឡើង២៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៣ គឺស្មើនឹង១,០៨%នៃផ.ស.ស.។

**ចំណាយចរន្តថវិការដ្ឋសរុប** មានចំនួន៨ ៧២០ ០៨៤,៣លានរៀល កើនឡើង១៥,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៣ ស្មើនឹង១២,៧១% នៃផ.ស.ស. ក្នុងនោះចំណាយចរន្តថវិកាថ្នាក់ជាតិមានចំនួន៨ ២៦៨ ៧០៣លានរៀល កើនឡើង១៤,៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៣ ស្មើនឹង១២,០៥%នៃផ.ស.ស. និងចំណាយចរន្តថវិកាថ្នាក់ក្រោមជាតិមានចំនួន៦២៣ ៨៥២,៥លានរៀល កើនឡើង២៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៣ ស្មើនឹង០,៩១%នៃផ.ស.ស.។ ចំណាយលើបន្ទុកបុគ្គលិក ត្រូវបានគ្រោងចំនួន៣ ៧៨២ ៨៧០លានរៀល មានសមាមាត្រ ៤៥,៧% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ គឺមានកំណើន ២៤,៩% ស្មើនឹង៧៥៣ ៦៨២លានរៀល ធៀបនឹង

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ត្រូវជា៥,៥១%នៃផ.ស.ស.។ ចំណាយក្រៅបន្ទុកបុគ្គលិក ត្រូវបានគ្រោងចំនួន៤ ៤៨៥ ៨៣៣លានរៀល មានសមាមាត្រ ៥៤,៣% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ គឺមានកំណើន ៧,២% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ត្រូវជា ៦,៥៤% នៃផ.ស.ស.។

ចំណាយចរន្តថវិកាថ្នាក់ជាតិ ត្រូវបានវិភាជទៅតាមវិស័យធំៗទាំងបួនដែលរួមមាន៖

(១)- **ចំណាយវិស័យសង្គមកិច្ច** មានទំហំ៤,៦១% នៃផ.ស.ស. កើនឡើង ១៥,៣%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៣ ក្នុងនោះ **ក្រសួងសុខាភិបាល** ត្រូវបានគ្រោងចំនួន៩៧៧ ៦៥១,៣ លានរៀលមានសមាមាត្រស្មើនឹង ១១,៨% នៃចំណាយចរន្តថវិកាថ្នាក់ជាតិនិងមានកំណើន ៨,៤% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៣ ត្រូវជា ១,៤២% នៃផ.ស.ស។ **ក្រសួងអប់រំ យុវជន និងកីឡា** ត្រូវបានគ្រោងចំនួន១ ៣៤២ ០៤៩លានរៀល មានសមាមាត្រស្មើនឹង ១៦,២% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ និងមានកំណើន ១៩,៩% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៣ ត្រូវជា ១,៩៦% នៃផ.ស.ស.។ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ត្រូវបានគ្រោងចំនួន ៥៦៥ ២៥៨,៤លានរៀល មានសមាមាត្រស្មើនឹង ៦,៨% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ និងមានកំណើន ៣៧,៥% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៣ ត្រូវជា ០,៨២% នៃផ.ស.ស.។

(២)- **ចំណាយវិស័យសេដ្ឋកិច្ច** មានទំហំ១,០២%នៃ ផ.ស.ស. កើនឡើង១៨,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៣ ក្នុងនោះ៖ **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** ត្រូវបានគ្រោងចំនួន ១៣៤ ២១៩លានរៀល មានសមាមាត្រ ១,៦% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ និងមានកំណើន ១០,៧% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៣ ត្រូវជា ០,២០% នៃផ.ស.ស. **ក្រសួងធនធានទឹក និងឧតុនិយម** ត្រូវបានគ្រោងចំនួន៦១ ៤១២,៤លានរៀល មានសមាមាត្រ ០,៧% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ និងមានកំណើន ៦% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៣ ត្រូវជា ០,០៩% នៃផ.ស.ស.។

(៣)- **ចំណាយវិស័យរដ្ឋបាលទូទៅ** មានទំហំ១,៦៣% នៃផ.ស.ស. កើនឡើង១,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៣ និង

(៤)- **ចំណាយវិស័យការពារជាតិនិងសន្តិសុខ** មានទំហំ២,៧៣% នៃផ.ស.ស. កើនឡើង១៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៣ ក្នុងនោះចំណាយបន្ទុកបុគ្គលិកមានចំនួន ១ ៣៥៩ ៦៩០លានរៀល ស្មើនឹង៧២,៦% នៃចំណាយសរុបរបស់ក្រសួង និងមានកំណើនប្រមាណ១៧,៩% ធៀបច្បាប់ថវិកាឆ្នាំ២០១៣។ លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលសូមគូសបញ្ជាក់ថាកំណើនក្នុងវិស័យការពារជាតិនិងសន្តិសុខ មានលក្ខណៈជាចំណាយសង្គមកិច្ចច្រើនជាង មិនមែនជាការបង្កើនចំណាយយោធូបករណ៍នោះទេ។

**ចំណាយមូលធនថវិការដ្ឋ** មានចំនួន៥ ៤៤៧ ៣៦៥លានរៀល ស្មើនឹង៧,៩៤%នៃផ.ស.ស. មានកំណើន៨,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៣។ ចំណាយនេះ ត្រូវបានបែងចែកជាបីប្រភេទគឺ៖ (១)- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេសចំនួន១ ៦៥៦ ៤៤១លានរៀល ស្មើនឹង២,៤១% នៃផ.ស.ស. កើនឡើង៥,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៣ (២)- ចំណាយ

សម្រាប់ការទូទាត់ប្រាក់កម្ចីមានចំនួន៣៣០ ៩២៤លានរៀល ស្មើនឹង ០,៤៨%នៃផ.ស.ស. កើនឡើង១៨,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៣ និង(៣)-ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសមានចំនួន៣ ៤៦០ ០០០ លានរៀល ស្មើនឹង៥,០៤% នៃផ.ស.ស. កើនឡើង ១០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៣។

១១- តម្រូវការចំណាយខាងលើ ឆ្លើយតបទៅនឹងតម្រូវការចាំបាច់ក្នុងការអភិវឌ្ឍធនធានមនុស្ស ការបង្កើនវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងសង្គម ដើម្បីពង្រឹងនិងពង្រីកមូលដ្ឋានសេដ្ឋកិច្ច សង្គម និងសមត្ថភាពស្ថាប័ន ជាមួយនឹងការលើកកម្ពស់កម្រិតជីវភាពរបស់មន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធ ដោយបានដំឡើងប្រាក់បៀវត្សមូលដ្ឋានប្រចាំខែ ជូនមន្ត្រីរាជការស៊ីវិលចំនួន៤០ ០០០រៀល សម្រាប់ក្របខ័ណ្ឌប្រភេទ "ក" និង ចំនួន៨០ ០០០រៀល សម្រាប់ក្របខ័ណ្ឌប្រភេទ "ខ" "គ" និង"ឃ" បានដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែចំនួន៤០ ០០០រៀល ជូនគ្រូចូលនិវត្តន៍ដែលបន្តបម្រើការងារជាគ្រូជាប់កិច្ចសន្យា និងបានដំឡើងប្រាក់ហូបប្រចាំថ្ងៃរបស់កងកម្លាំងប្រដាប់អាវុធពីចំនួន១ ៥០០រៀល ក្នុងមួយថ្ងៃ ទៅចំនួន៤ ០០០រៀល ក្នុងមួយថ្ងៃ ព្រមទាំងបានផ្តល់ប្រាក់ហូបដល់អង្គភាពសម្រាប់ការហ្វឹកហាត់របស់យោធាចំនួន៣០០០រៀល ក្នុងមួយថ្ងៃ។ គោលនយោបាយថ្មីនេះ នឹងធ្វើឲ្យប្រាក់បៀវត្សប្រចាំខែទាបបំផុតកើនពី ៣២០០០០រៀល ដល់ ៤២០ ០០០រៀល។ **ចំណាយបន្ទុកបុគ្គលិកកើនពី ៤២% ដល់ ៤៥,៧៥% នៃចំណាយចរន្តសរុប ស្មើនឹង៥,៥១% នៃផ.ស.ស.**។ កត្តានេះបានបង្កើតជាសម្ពាធបន្ថែមទៀតដល់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ដែលចាំបាច់តម្រូវឲ្យមានការខិតខំសន្សំថវិកាពីចំណាយចរន្តក្រៅពីបន្ទុកបុគ្គលិក ដើម្បីរក្សាអតិរេកថវិកាចរន្តឲ្យបានក្នុងកម្រិតប្រមាណ២,២៨% នៃផ.ស.ស. និងកាត់បន្ថយឱនភាពថវិកាសរុបពី -៦,០៥% នៃផ.ស.ស. ក្នុងឆ្នាំ២០១៣ ឲ្យនៅត្រឹមកម្រិតប្រមាណ -៥,៣២% នៃផ.ស.ស. ស្របតាមគោលដៅរបស់រាជរដ្ឋាភិបាលគឺកាត់បន្ថយឱនភាពថវិកាសរុបជាបណ្តើរៗទៅរកកម្រិតដែលធានាចីរភាពថវិកាគឺប្រមាណ -៣% នៃផ.ស.ស. ដូចមុនវិបត្តិ និងសន្សំអតិរេកសាច់ប្រាក់ឡើងវិញ ដើម្បីបង្កើនទុនបម្រុងរបស់រដ្ឋសម្រាប់ត្រៀមទប់ទល់វិបត្តិនិងហានិភ័យដែលអាចកើតឡើងដោយថាហេតុពីខាងក្នុងនិងពីខាងក្រៅ។ ដោយឡែក ទោះបីជាចំណាយក្រៅបន្ទុកបុគ្គលិកមានកំណើនតិចតួច ដោយសារសម្ពាធនៃការបង្កើនបៀវត្សក្តី រាជរដ្ឋាភិបាលនៅតែមានជំនឿយ៉ាងមុតមាំថា គោលដៅជាសារវន្តនៃថវិកា ដែលបានដាក់ចេញនៅតែអាចសម្រេចបានតាមរយៈការបង្កើនប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិនៃការគ្រប់គ្រងចំណាយ ទាំងចំណាយថវិកាចរន្តនិងចំណាយមូលធន។

១២- *ដើម្បីបំពេញតាមគោលនយោបាយចំណាយខាងលើ រាជរដ្ឋាភិបាលប្តេជ្ញាបន្តពង្រឹងនិងពង្រីកការប្រមូលចំណូលបន្ថែមទៀត ជាពិសេស បន្តកែលម្អគោលនយោបាយនិងពង្រឹងការអនុវត្តវិធានការរដ្ឋបាល រួមទាំងវិធានការមុតស្រួចក្នុងការកែលម្អអភិបាលកិច្ចផង នៅក្នុងផ្នែកគយពន្ធដារ និងចំណូលមិនមែនសារពើពន្ធ ដោយម៉ឺងម៉ាត់ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងបន្តជំរុញការអនុវត្តពន្ធលើអចលនទ្រព្យ*

*ដើម្បីជាប្រយោជន៍ដល់ថវិកាថ្នាក់ក្រោមជាតិដែលរួមមាន ៣ថ្នាក់គឺរាជធានី ខេត្ត ក្រុង ស្រុក និងឃុំសង្កាត់។* ចំណូលក្នុងប្រទេសនៃថវិការដ្ឋសរុបសម្រាប់ឆ្នាំ២០១៤ ត្រូវសម្រេចឲ្យបានចំនួន ១០ ៥១៧ ៤៤៩,៣លានរៀល កើនឡើង១៧% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៣ ស្មើនឹង១៥,៣៣% នៃផ.ស.ស. **ឬត្រូវមានកំណើន១,០៨% នៃផ.ស.ស.** ធៀបនឹងការប៉ាន់ស្មានការអនុវត្តឆ្នាំ២០១៣។ កំណើនចំណូលជាង ១% នៃផ.ស.ស. នេះ គឺជាគោលដៅប្រកបដោយមហិច្ឆតា បើធៀបនឹងគោលដៅជាមធ្យម០,៥% នៃផ.ស.ស.ក្នុងមួយឆ្នាំ នៅក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ នៅក្នុងរចនាសម្ព័ន្ធចំណូលក្នុងប្រទេសនេះ ១៤,៤៩% នៃផ.ស.ស. ជាចំណូលថវិកាថ្នាក់ជាតិនិង ០,៨៣%នៃផ.ស.ស. ជាចំណូលថវិកាថ្នាក់ក្រោមជាតិ។ មើលតាមទិដ្ឋភាពម្យ៉ាងទៀត ចំណូលចរន្តថវិការដ្ឋសរុបមាន១៤,៩៩% នៃផ.ស.ស. និងចំណូលមូលធនក្នុងប្រទេសមាន០,៣៤%នៃផ.ស.ស.។ ចំណូលចរន្តថវិកាថ្នាក់ជាតិមាន១៤,១៥% នៃផ.ស.ស. បានមកពីចំណូលសារពើពន្ធចំនួន១២,១១% នៃផ.ស.ស. ដែលក្នុងនោះ ៦,៧៥%នៃផ.ស.ស. ជាចំណូលគយនិងរដ្ឋាករ ៥%នៃផ.ស.ស. ជាចំណូលពន្ធដារ ០,៣៦%នៃផ.ស.ស. ជាចំណូលសារពើពន្ធផ្សេងៗទៀត និងបានមកពីចំណូលមិនមែនសារពើពន្ធចំនួន២,០៥%នៃផ.ស.ស.។

## III- បញ្ហាប្រឈមនិងវិធានការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤

**១៣-** ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ដើម្បីសម្រេចឲ្យបានតាមគោលដៅនៃគោលនយោបាយដូចបានគូសបញ្ជាក់ខាងលើ មានបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

ទី១- សេដ្ឋកិច្ចពិភពលោកស្ថិតក្នុងភាពផុយស្រួយ ដោយសារសេដ្ឋកិច្ចអឺរ៉ុបនៅមានហានិភ័យនៃការធ្លាក់ចុះនិងកំណើនយឺតនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក ព្រមទាំងភាពថមថយនៃសន្ទុះសេដ្ឋកិច្ចនៃបណ្តាប្រទេសសេដ្ឋកិច្ចកំពុងងើបឡើង ជាពិសេស ចិន និង ឥណ្ឌា ដែលកត្តាទាំងនេះ អាចនឹងបង្កជាបច្ច័យអវិជ្ជមានដល់សេដ្ឋកិច្ចកម្ពុជា។ ជាមួយគ្នានេះផលប៉ះពាល់នៃគ្រោះទឹកជំនន់ឆ្នាំ២០១៣ ក៏បានបង្កើនបន្ទុកបន្ថែមទៀតទៅលើថវិកា ក៏ដូចជាអាចមានផលប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចជាតិជាទូទៅ។

ទី២- ពិពិធកម្មមូលដ្ឋានកំណើនសេដ្ឋកិច្ចជាមួយនឹងការរីកចម្រើននៃប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុនៅមានកម្រិត ធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាត្រូវបន្តពឹងផ្អែកលើទីផ្សារខាងក្រៅនិងងាយរងនូវឥទ្ធិពលពីខាងក្រៅ។ មូលដ្ឋានគ្រឹះនៃកំណើននិងជាសសរទ្រូងដ៏សំខាន់នៃសេដ្ឋកិច្ចកម្ពុជា គឺវិស័យកសិកម្ម ផ្នែកឧស្សាហកម្មកាត់ដេរ ផ្នែកសេវាទេសចរណ៍ និងសំណង់ ដែលកំពុងស្ថិតក្នុងដំណាក់កាលអភិវឌ្ឍន៍នៅពុំទាន់រឹងមាំនៅឡើយ ហើយកម្លាំងពលកម្មនៅមានផលិតភាពទាប ព្រមទាំងកំពុងរងហានិភ័យពីខាងក្រៅ និងការប្រកួតប្រជែងកាន់តែខ្លាំងឡើងជាមួយបណ្តាប្រទេសនៅក្នុងតំបន់និងនៅលើទីផ្សារអន្តរជាតិ។ ដោយឡែក វិស័យកសិកម្មដែលមានប្រមាណជាង៣០% នៃផលិតផលក្នុងស្រុកសរុប និងជាមូលដ្ឋានស្រូបយកការងារប្រមាណជាង៦០% ក៏នៅមានទិន្នផលនិងផលិតភាពទាបដែរ ហើយ

នៅមិនទាន់ប្រើប្រាស់ឲ្យអស់សក្តានុពលនៅឡើយ ព្រមទាំងបាននិងកំពុងបន្តទទួលការគម្រាមកំហែងកាន់តែខ្លាំងពីគ្រោះធម្មជាតិដោយសារបាតុភូតនៃការប្រែប្រួលអាកាសធាតុ។

ទី៣- រាជរដ្ឋាភិបាលកំពុងត្រូវការបង្កើនចំណាយសង្គមកិច្ច ដើម្បីបង្កើនប្រសិទ្ធភាពសេវាសាធារណៈ ពិសេសសេវាអប់រំ និងសុខាភិបាល បង្កើនចំណាយកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ពិសេសផ្លូវថ្នល់និងប្រព័ន្ធស្រោចស្រព ដើម្បីជំរុញកំណើនសេដ្ឋកិច្ចក្នុងគោលដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ បង្កើនចំណាយបៀវត្សសំដៅលើកកម្ពស់ផលិតភាពការងារ និងធានាឲ្យមន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធមានជីវភាពសមរម្យ ព្រមទាំងបង្កើនធនធានបម្រុងរបស់រដ្ឋសំដៅធានាឲ្យមានថវិកាសម្រាប់ចំណាយចៃដន្យចាំបាច់ ពង្រឹងភាពធន់នៃសេដ្ឋកិច្ចជាតិ ត្រៀមការពារអធិបតេយ្យជាតិនិងបូរណភាពទឹកដី ព្រមទាំងដោះស្រាយផលវិបាកនៃគ្រោះធម្មជាតិជាយថាហេតុ។ ជាមួយនឹងតម្រូវការបង្កើនចំណាយ កម្ពុជាក៏កំពុងប្រឈមនឹងនិន្នាការថយចុះខាងចំណូលគយ ដែលជាផលវិបាកនៃការអនុវត្តកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន និងកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីផ្សេងៗទៀត។ លើសពីនេះ រាជរដ្ឋាភិបាលបានធ្វើការកាត់បន្ថយឬទម្លាក់មកសូន្យនូវអត្រាពន្ធគយលើមុខទំនិញមួយចំនួន ដើម្បីជំរុញអគ្គិសនីនីយកម្មជនបទ និងសម្រាប់ជួយដល់វិស័យកសិកម្ម និងសហគ្រាសធុនតូចនិងមធ្យម ព្រមទាំងផលិតកម្មបម្រើទីផ្សារក្នុងស្រុក។ ម្យ៉ាងវិញទៀត ការប្រមូលពន្ធក្នុងស្រុកមានការលំបាកនិងស្មុគស្មាញជាងការប្រមូលពន្ធនាំចូលតាមមាត់ច្រកទ្វារភាគីតំបន់និងអន្តរជាតិ ដែលទាមទារសមត្ថភាពជំនាញ និងបច្ចេកវិទ្យាខ្ពស់ និងត្រូវការនូវការអប់រំដល់អ្នកជាប់កាតព្វកិច្ចពន្ធក្នុងពេលដែលវប្បធម៌បង់ពន្ធនៅមានកម្រិតទាបនៅឡើយ។ **កត្តានេះបានធ្វើឲ្យការកាត់បន្ថយឱនភាពថវិកាឆ្ពោះទៅរកការរក្សាអតិរេកសាច់ប្រាក់ឡើងវិញមានការលំបាក។** ការប្រមូលចំណូលមិនមែនសារពើពន្ធមិនទាន់មានប្រសិទ្ធភាពនៅឡើយ ដែលទាមទារឲ្យមានការដាក់ចេញនិងអនុវត្តវិធានការមុតស្រួចនិងម៉ឺងម៉ាត់។

**១៤- ដើម្បីជម្នះបានលើបណ្តាបញ្ហាប្រឈមខាងលើប្រកបដោយភាពស័ក្តិសិទ្ធិនិងប្រសិទ្ធភាព ព្រមទាំងមានលក្ខណៈជាប្រព័ន្ធ រាជរដ្ឋាភិបាលនឹងត្រូវបន្តអប្បមាទជាប្រចាំនិងដាក់ចេញនូវវិធានការទាន់ពេលវេលា ព្រមទាំងនឹងបន្តជំរុញបន្ថែមទៀតនូវការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវកម្មវិធីកែទម្រង់លើគ្រប់វិស័យឲ្យកាន់តែស៊ីជម្រៅ ពិសេសបន្តជំរុញអនុវត្តនូវគោលនយោបាយ កម្មវិធីអភិវឌ្ឍន៍ និងកម្មវិធីកែទម្រង់សំខាន់ៗ និងចាំបាច់មួយចំនួនដូចជាៈ**

ទី១. បន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈដ៏ប្រុងប្រយ័ត្ន គួបផ្សំនឹងគោលនយោបាយរូបិយវត្ថុដ៏សមស្រប និងកំណែទម្រង់រចនា-សម្ព័ន្ធចាំបាច់នានា ដើម្បីធានាបន្តសម្រេចឲ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងកំណើនសេដ្ឋកិច្ចខ្ពស់ និងប្រកបដោយចីរភាព ក្នុងបរិការណ៍នៃអត្រាអតិផរណាទាបសមរម្យ។

ទី២. បន្តពង្រឹងនិងពង្រីកប្រព័ន្ធធនាគារ វិស័យធានារ៉ាប់រង និងទីផ្សារមូលបត្រ ក្នុងក្រប-ខ័ណ្ឌនៃការបន្តជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុទាំងមូល ដើម្បីបង្កើនការកៀរគរធនធានហិរញ្ញវត្ថុ

ប្រកបដោយប្រសិទ្ធភាព និងបង្កើនសក្តានុពលភាព និងកាលានុវត្តភាពដល់ការធ្វើហិរញ្ញប្បទាន និងការអភិវឌ្ឍវិស័យឯកជន។

ទី៣. លើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលចំណូលសារពើពន្ធ ជាពិសេសការចាត់វិធានការរដ្ឋបាលនិងវិធានការកែលម្អអភិបាលកិច្ចផ្នែកគយនិងពន្ធដារ ទាំងសម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែងខាងមុខ និងវិធានការរឹតបន្តឹងចំពោះការគ្រប់គ្រងនិងប្រមូលចំណូលមិនមែនសារពើពន្ធនានា។ ខាងផ្នែកចំណាយវិញ រាជរដ្ឋាភិបាលនឹងចាត់វិធានការបង្កើនប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិនៃចំណាយ តាមរយៈការកែលម្អការវិភាជថវិកាឲ្យចំទិសដៅ ទៅតាមអាទិភាពគោល-នយោបាយ និងការលើកកម្ពស់ភាពស័ក្តិសិទ្ធិនៃប្រតិបត្តិការចំណាយ ជាពិសេសការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយក្នុងផ្នែកចំណាយថវិកានិងការខ្ជះខ្ជាយថវិកា។

ទី៤. បង្កើនការយកចិត្តទុកដាក់ខ្ពស់លើការបង្កើនគុណភាពសេវាវិស័យអប់រំ ជំនាញបច្ចេក-ទេស និងវិជ្ជាជីវៈ សុខាភិបាល និងការកសាងធនធានមនុស្ស ព្រមទាំងការងារបង្កើនសុវត្ថិភាពសង្គម។

ទី៥. បង្កើនប្រសិទ្ធភាពនៃការវិនិយោគលើការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងបង្កើតបរិស្ថានអនុគ្រោះដល់ការអភិវឌ្ឍវិស័យឯកជន ក្នុងនោះរួមទាំងការលើកកម្ពស់យន្តការភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជន ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចនិងបង្កើតការងារ។

ទី៦. បន្តជំរុញនិងបង្កើនការលើកស្ទួយវិស័យកសិកម្ម កសិឧស្សាហកម្ម និងជួយគាំទ្រដល់សហគ្រាសធុនតូចនិងមធ្យម ពិសេសជំរុញការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ព្រមទាំងជំរុញនិងលើកទឹកចិត្តដល់ផលិតកម្មនៃបណ្តាកសិផលមួយចំនួនទៀត ដែលកំពុងមានសក្តានុពលខ្ពស់ ដូចជា ដំឡូងមី ពោត និងកៅស៊ូ។

ទី៧. បន្តជំរុញការអនុវត្តកំណែទម្រង់ការគ្រប់គ្រងដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបោសសម្អាតមីន ដោយផ្តោតជាសំខាន់លើការពង្រឹងប្រព័ន្ធគ្រប់គ្រងការបែងចែកដីធ្លីប្រកបដោយសមធម៌ និងការប្រើប្រាស់ដីធ្លីប្រកបដោយប្រសិទ្ធភាព។

ទី៨. បន្តជំរុញការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ ពិសេសការកែលម្អការគ្រប់គ្រងធនធានមនុស្ស ដើម្បីបង្កើនផលិតភាព និងប្រសិទ្ធភាពការងារ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងជំរុញអនុវត្តគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ ឲ្យមានភាពស័ក្តិសិទ្ធិនិងប្រសិទ្ធភាពខ្ពស់ ជាពិសេស បង្កើតយន្តការនិងបង្កើនប្រសិទ្ធភាពនៃការត្រួតពិនិត្យក្របខ័ណ្ឌមន្ត្រីរាជការ និងពង្រឹងការផ្តល់ទិដ្ឋាការឲ្យរើសមន្ត្រីថ្មីបន្ថែម ដោយផ្អែកលើការវិភាគលើតម្រូវការជាក់ស្តែងនិងលទ្ធ-ភាពថវិកាជាតិ ព្រមទាំងផ្សារភ្ជាប់ទៅនឹងការគ្រប់គ្រងក្របខ័ណ្ឌមន្ត្រីរាជការចូលនិវត្តន៍។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងពិនិត្យនិងរៀបចំឡើងវិញ នូវគោលនយោបាយនិងគោលការណ៍ដំឡើង និងផ្តល់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ រួមទាំងការដំឡើងបៀវត្សមូលដ្ឋានប្រចាំឆ្នាំ ការដំឡើងកាំប្រាក់ការអនុវត្តប្រាក់បំណាច់មុខងារ ការផ្តល់ប្រាក់ឧបត្ថម្ភផ្សេងៗ ដូចជា ប្រាក់ម៉ោង ប្រាក់យាម ប្រាក់

បេសកកម្ម និងចំណាយប្រតិបត្តិការអាទិភាពជាដើម ព្រមទាំងការបើកផ្តល់ប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ ដើម្បីធានាសមធម៌ តម្លាភាព សង្គតិភាព និងប្រសិទ្ធភាព។

ទី៩ .បន្តជំរុញការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ពិសេសការរៀបចំរចនាសម្ព័ន្ធរដ្ឋបាល ច្បាប់ និងលិខិតគតិយុត្តិផ្សេងៗ ដើម្បីអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(ប.អ.ជ.គ) និងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវសហការរៀបចំកម្មវិធីនិងសកម្មភាពការងារឲ្យបានច្បាស់លាស់គ្រប់ជ្រុងជ្រោយជាជំហានៗប្រកបដោយភាពហ្មត់ចត់ ក្នុងការពង្រឹងសមត្ថភាពរដ្ឋបាល បច្ចេកទេស និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់គ្រប់ស្ថាប័ននិងអង្គភាពថ្នាក់ក្រោមជាតិ ដើម្បីធានាការអនុវត្តប្រកបដោយភាពរលូន នូវការផ្ទេរអំណាច ការទទួលខុសត្រូវ មុខងារ និងធនធានពីថ្នាក់ជាតិ ក្នុងគោលដៅសម្រេចបាននូវការកែលម្អសេវាសាធារណៈនៅតាមមូលដ្ឋានប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងគណនេយ្យភាព។

ទី១០ .បន្តជំរុញការអនុវត្តកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ពិសេស ការពង្រឹងសមត្ថភាពដឹកនាំ វិជ្ជាជីវៈជំនាញ និងការគ្រប់គ្រងធនធានមនុស្ស និងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ព្រមទាំងការកែសម្រួលរចនាសម្ព័ន្ធកងឯកភាពប្រយុទ្ធ ដើម្បីធានាការប្រើប្រាស់និងគ្រប់គ្រងកងកម្លាំងប្រដាប់អាវុធប្រកបដោយភាពស័ក្តិសិទ្ធិនិងប្រសិទ្ធភាពខ្ពស់។

ទី១១. បន្តជំរុញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី២ ជាពិសេស៖

- បន្តជំរុញការអនុវត្តផែនការសកម្មភាពជំហានទី២ គឺការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុដោយផ្តោតលើការរៀបចំនិងដាក់ឲ្យអនុវត្តនូវចំណាត់ថ្នាក់ថវិកាថ្មីបន្ថែមទៀត អង្គភាពថវិកា ស្តង់ដារគណនេយ្យ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនិងការសាកល្បងការគ្រប់គ្រងហិរញ្ញវត្ថុដោយប្រព័ន្ធព័ត៌មានវិទ្យា។
- បន្តពង្រឹងភាពជឿទុកចិត្តលើថវិកានៃជំហានទី១ តាមរយៈការបន្តជំរុញកែលម្អនីតិវិធីចំណាយ បន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ដើម្បីធានាឲ្យការបើកផ្តល់ថវិកាបានទាន់ពេលវេលា។
- រៀបចំនិងដាក់ឲ្យអនុវត្ត "**យុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**" ដើម្បីរក្សាស្ថិរភាពនិងនិរន្តរភាពចំណូល ពិសេស ផ្តោតការយកចិត្តទុកដាក់លើការកសាងនិងពង្រឹងការអនុវត្តក្របខ័ណ្ឌច្បាប់ យន្តការគ្រប់គ្រង និងការប្រមូលពន្ធនិងអាករ ព្រមទាំងចំណូលមិនមែនសារពើពន្ធ រួមទាំងចំណូលពីធនធានធម្មជាតិផង។
- បន្តជំរុញការអនុវត្តឯកសារទស្សនាទានស្តីអំពីទិសដៅយុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជាឆ្នាំ២០១៣-២០២០ ជាពិសេសពង្រឹងនិងបង្កើនការអនុវត្តផែនការយុទ្ធសាស្ត្រថវិកានិងថវិកាកម្មវិធី ដែលជាមូលដ្ឋានដ៏សំខាន់និងចាំបាច់ ក្នុងការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាជា

បណ្តើរៗ និងដើម្បីឈានទៅបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងការបង្កើនគណនេយ្យភាពចំពោះសមិទ្ធកម្ម ដែលជាគោលដៅនៃដំហានទី៣និងទី៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ទី១២. បន្តជំរុញការអនុវត្តច្បាប់ប្រឆាំងនឹងអំពើពុករលួយ ពិសេស ការបន្តរៀបចំនិងពង្រឹងសមត្ថភាពអង្គភាពប្រឆាំងអំពើពុករលួយ ដើម្បីអាចដំណើរការនិងប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពក្នុងការអប់រំ ទប់ស្កាត់ និងបោសសម្អាតអំពើពុករលួយ។

## III- **សេចក្តីសន្និដ្ឋាន**

**១៥-** ថវិកាឆ្នាំ២០១៤នេះ គឺពិតជាឧបករណ៍គោលនយោបាយដ៏មានសារៈសំខាន់បំផុតសម្រាប់ឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ ដែលបានស្តែងឡើងតាមរយៈការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ពិសេសតាមរយៈការជំរុញអនុវត្តនូវ "**គោលដៅជាយុទ្ធសាស្ត្រ ៤**" និង "**វិស័យអាទិភាព ៤**" នៃ »**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣**«។ ទន្ទឹមនឹងនេះ ថវិកាឆ្នាំ២០១៤ ក៏បានឆ្លុះបញ្ចាំងនូវការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់និងមុតស្រួចរបស់រាជរដ្ឋាភិបាល ក្នុងការបន្តរក្សាស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម បន្តពង្រឹងនិងពង្រីកការអនុវត្តលទ្ធិប្រជាធិបតេយ្យ បន្តរក្សាឲ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងធានាបាននូវភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីសម្រេចបាននូវគោលដៅជាសារវន្តនៃការទ្រទ្រង់កំណើនសេដ្ឋកិច្ចនិងការកាត់បន្ថយភាពក្រីក្រ ក៏ដូចជាក្នុងការអនុវត្តកម្មវិធីអភិវឌ្ឍន៍ និងកំណែទម្រង់លើគ្រប់វិស័យឲ្យកាន់តែស៊ីជម្រៅនិងឲ្យមានលទ្ធផលជាក់ស្តែង ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃដំណើរផ្លាស់ប្តូរជារចនាសម្ព័ន្ធនៃសេដ្ឋកិច្ចសង្គមកម្ពុជាផង និងឆន្ទៈរបស់ប្រជាពលរដ្ឋផង ព្រមទាំងដើម្បីពង្រីកនិងពង្រឹងមូលដ្ឋាន សម្រាប់កំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍសម្រាប់រយៈពេលវែងផងដែរ។

**១៦-** ក្នុងន័យនេះ **ថវិកាឆ្នាំ២០១៤ អាចប្រសិទ្ធនាមបានថា «ជាថវិកានៃការចាប់ផ្តើមដំណើរការផ្លាស់ប្តូររបស់កម្ពុជា ឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយគុណភាពនិងចីរភាព ការគិតគូរអំពីតុល្យភាពនៃកំណើនសេដ្ឋកិច្ចនិងការបែងចែកផលកំណើនសេដ្ឋកិច្ចភ្ជាប់ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ និងបំណងប្រាថ្នារបស់ប្រជាជន ព្រមទាំងការគិតគូរដល់ការអភិវឌ្ឍរយៈពេលវែងក្នុងបរិការណ៍សមាហរណកម្មស៊ីជម្រៅក្នុងតំបន់ ការវិវឌ្ឍនៃសកលភាវូបនីយកម្ម ក៏ដូចជាការពង្រឹងសមត្ថភាពគ្រប់គ្រងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ឲ្យស្របទៅនឹងដំណាក់កាលថ្មីរបស់កម្ពុជា»**។ អាទិភាពចំណាយថវិកាឆ្នាំ២០១៤ បានឆ្លុះបញ្ចាំងឲ្យឃើញយ៉ាងប្រត្យក្សនូវនិយមន័យខាងលើ ជាពិសេស វិស័យអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ សុខាភិបាល កសិកម្ម កសិឧស្សាហកម្ម អភិវឌ្ឍន៍ជនបទ ការបន្តពង្រឹងនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជាផ្លូវថ្នល់ ស្ពាន ប្រព័ន្ធស្រោចស្រព និងអគ្គិសនី ដែលជាមុខព្រួញសំខាន់ចាំបាច់និងអាទិភាពរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនឹងនេះ ថវិកាឆ្នាំ២០១៤



A

ក៏បានបញ្ជាក់នូវការប្តេជ្ញាចិត្តក្នុងការខិតខំបង្កើនប្រសិទ្ធភាពនៃការកៀរគរចំណូល តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាលនិងវិធានការគោលនយោបាយ ជាពិសេសការលើកកម្ពស់វប្បធម៌បង់ពន្ធ ការបង្ក្រាបអំពើរត់ពន្ធ និងការគេចវេះពន្ធគ្រប់រូបភាព ឲ្យដល់ឫសគល់ ព្រមទាំងការកែលម្អអភិបាលកិច្ចក្នុងការប្រមូលចំណូល។

**១៧**- រាជរដ្ឋាភិបាលមានជំនឿយ៉ាងមុតមាំថា អ្វីដែលបានលើកឡើងខាងលើនេះ គឺស្របទៅនឹងឆន្ទៈរបស់ប្រជាជន ក៏ដូចជាតម្រូវការនៃការអភិវឌ្ឍរបស់កម្ពុជា ហើយដែលចាំបាច់ត្រូវអនុវត្តឲ្យមានលទ្ធផលជាក់ស្តែង។ ក្នុងន័យនេះ រាជរដ្ឋាភិបាលប្តេជ្ញាចិត្តសម្រេចឲ្យបាននូវគោលដៅនិងវិធានការទាំងឡាយដែលបានលើកឡើងខាងលើ តាមរយៈការប្រកាន់ខ្ជាប់នូវអភិក្រមការងារថ្មី៤យ៉ាង គឺ «**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល និងព្យាបាល**»។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាល សូមអំពាវនាវដល់តួអង្គពាក់ព័ន្ធទាំងអស់ ផ្តល់ការគាំទ្រនិងការចូលរួមអនុវត្តដោយសកម្ម ដោយឈរលើគោលការណ៍សាមគ្គីភាព ឯកភាពជាតិ និងតម្កល់ផលប្រយោជន៍របស់ជាតិនិងប្រជាជនជាធំ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមរដ្ឋសភាមេត្តាពិនិត្យនិងផ្តល់ការអនុម័តលើសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤នេះ ដោយចាត់ទុកជាការប្រញ្ញាប់ដោយក្តីអនុគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**